ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ២០/១១-សិប្បករអង្គរ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **អ៊ុក រី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **គង់ ផល្លះ**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន សិប្បករអង្គរ**

អាសយដ្ឋាន : ភូមិវិហារចិន សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ : ០១២ ៤២៨ ៥២៧ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោកស្រី កាតីរីន ណុប | នាយិកាធនធានមនុស្ស |
| ២- លោក វីដាណូ កៃណែម | អគ្គលេខាធិការក្រុមហ៊ុន សិប្បករអង្គរ |
| ៣- លោក ពុធ សុភា | នាយកផ្នែកផលិតកម្ម |
| ៤- លោក ហួន សុខភានាថ | មន្ត្រីផ្នែកច្បាប់របស់ CAMFEBA |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ : - **សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា**

- **សហជីពកម្មករនិយោជិតសិប្បកម្មអង្គរ នៃក្រុមហ៊ុនសិប្បករចំរុះអង្គរ**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

អាសយដ្ឋាន : ភូមិវាល ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ : ០១២ ៧៣៦ ២៧០ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិតៈ

១- លោកស្រី កេន ឆេងឡាង អគ្គលេខាធិការសហព័ន្ធ

២- លោក ទេព ចយ ប្រធានសហជីពកម្មករនិយោជិតសិប្បកម្មអង្គរ

៣- លោកស្រី លឹម វិច អនុប្រធានសហជីព

៤- លោក ជួម ជី សកម្មជនសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតំឡើងប្រាក់ឈ្នួលឱ្យពួកគេចំនួន ៦ សេន ក្នុងមួយម៉ោងផលិត លើប្រាក់ម៉ោងផលិតដែលមានស្រាប់។ (អ្នកស្រី កាតឺរីន ណុប តំណាងក្រុមហ៊ុនបានតំឡើងជូនកម្មករលើការទាមទារនេះចំនួន ៣ សេន)។ កម្មករមិនព្រមទទួលយកការតំឡើងចំនួន ៣ សេន នេះទេ។

២- កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលពីសាមសិបប្រាំភាគរយ ទៅហាសិបភាគរយ ចំពោះការផលិតខូចដោយអចេតនា។ (អ្នកស្រី កាតឺរីន ណុប តំណាងក្រុមហ៊ុន បានបង្ហាយហេតុផលថា ការផលិតខូចនេះ ធ្វើឱ្យក្រុមហ៊ុនបាត់បងទុនលើការចំណាយទិញវត្ថុធាតុដើមមកវិញយ៉ាងច្រើន ហើយវត្ថុធាតុដើមកំពុងតែឡើងថ្លៃមិនឈប់ដែរ ក្រុមហ៊ុននៅរក្សាផ្តល់ជូនកម្មករចំនួនសាបសិបប្រាំភាគរយដដែល)។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៤)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០០២ មកប ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១។

THE ARBITRATION COUNCIL

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ (វេលាម៉ោង ១៤:00 នាទី រសៀល) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត ដែលធ្វើការទាមទារចំនួន ២ ចំណុច ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយជាបន្ត នៅថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១១ ប៉ុន្តែពុំបានទទួលលទ្ធផលសះជានឹងគ្នា លើការទាមទារចំនួន០២ចំណុចនេះទេ ។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ចំរុះសិប្បករអង្គរ លេខ ០០២ មកប ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ១៤:00 នាទី រសៀល ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ នៅថ្ងៃសវនាការ ភាគីទាំងពីរបានស្នើឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០២ ចំណុចនេះបន្ថែមទៀត ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សា ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ០១ ចំណុច គឺចំណុចវិវាទទី២ ហើយនៅសល់ចំណុចមិនសះជាចំនួនមួយចំណុច គឺចំណុចវិវាទទី១ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើវិវាទ ដែលនៅសល់នេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន សិប្បករអង្គរ ជូនលោកស្រី កាតឹរីន ណុប ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១ ។

២- សារណាសំរាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើសំណុំរឿងក្រុមហ៊ុន សិប្បករអង្គរ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ។

៣- លក្ខន្តិកៈក្រុមហ៊ុន សិប្បករអង្គរ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ ។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជិការពាណិជ្ជកម្មក្រុមហ៊ុន សិប្បករអង្គរ លេខ ០៦៩៥ ពណ.ចបព ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ ។

៥- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចំរុះសិប្បករអង្គរ ធ្វើនៅខែមិនា ឆ្នាំ ២០០៨។

៦- តារាងមធ្យមភាគប្រាក់បៀវត្សរបស់សិប្បករទទួលប្រាក់កំរៃតាមបរិមាណផលិតផល ខែមករា-ធ្នូ ឆ្នាំ២០១០ និងខែមករា ឆ្នាំ២០១១ ។

៧- លិខិតជូនដំណឹងរបស់ការិយាល័យធនធានមនុស្ស លេខ ១១០១០៤ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ ២០១១ ស្តីពីការតម្លើងប្រាក់ម៉ោងផលិតចំនួន ០.០៣ សេន។

៨- កំណត់ហេតុនៃការជួបចរចារជាមួយសហជីពស្តីពីការស្នើសុំតម្លើងប្រាក់ម៉ោងផលិត ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១ ។

៩- លិខិតអញ្ជើញលោកអគ្គនាយកក្រុមហ៊ុន ចំរុះសិប្បករអង្គរ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប លេខ ០០២ មកប ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ដើម្បីចូលរួមផ្សះផ្សាវិវាទការងារជាមួយសហជីព។

១០- កំណត់ហេតុសាកសួរព័ត៌មានពីតំណាងនិយោជក ក្រុមហ៊ុន ចំរុះសិប្បករអង្គរ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ។

១១- សេចក្តីជូនដំណឹងរបស់ការិយាល័យផលិតកម្មសូត្រ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីដំណោះស្រាយលើបញ្ហាផលិតផល ដែលផលិតខូចគុណភាព ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- សារណាសង្ខេបវិវាទការងារក្នុងសំណុំរឿងលេខ ២០/១១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ។

២- លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ៦៦៦ កប/អក/វក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ជំរាបមកលោកប្រធានសហជីពកម្មករនិយោជិតសិប្បកម្មអង្គរនៃក្រុមហ៊ុនសិប្បករចំរុះអង្គរ ស្តីពីការសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២ ។

៣- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករនិយោជិតសិប្បកម្មអង្គរនៃក្រុមហ៊ុនសិប្បករចំរុះអង្គរ លេខ ១២១០ កប/វក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៧ ។

៤- លិខិតរបស់សហជីពកម្មករនិយោជិតសិប្បកម្មអង្គរនៃក្រុមហ៊ុនសិប្បករចំរុះអង្គរ ចុះថ្ងៃទី៣០ ខែ

THE ARBITRATION COUNCIL

វិច្ឆិកា ឆ្នាំ២០១០ គោរពជូនលោកនាយកក្រុមហ៊ុនចំរុះសិប្បករអង្គរ ស្តីពីការសុំណាត់ជួបចរចារពីបញ្ហាតម្លើងកាំប្រាក់ចំនួន ៦ សេន ក្នុងមួយម៉ោង ។

៥- លិខិតរបស់សហជីពកម្មករនិយោជិតសិប្បកម្មអង្គរនៃក្រុមហ៊ុនសិប្បករចំរុះអង្គរ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១ គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ស្តីពីការប្តឹងនាយកក្រុមហ៊ុនចំរុះសិប្បករអង្គរ ពីបទមិនព្រមជួបចរចារជាមួយសហជីព ។

៦- កំណត់ហេតុសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិត ក្រុមហ៊ុន ចំរុះសិប្បករអង្គរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ ។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ចំរុះសិប្បករអង្គរ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ចំរុះសិប្បករអង្គរ លេខ ០០២ មកប ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ចំរុះសិប្បករអង្គរ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១១៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១១៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន សិប្បករអង្គរ ជាក្រុមហ៊ុនចំរុះរដ្ឋ បានចាប់បើកដំណើរការនៅឆ្នាំ២០០៣ មានទីតាំងបច្ចុប្បន្នស្ថិតនៅ ភូមិវិហារចិន សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មានជួលកម្មករនិយោជិតចំនួនប្រមាណ ១ ០៧៨ នាក់ ។

THE ARBITRATION COUNCIL

- នៅក្នុងក្រុមហ៊ុនមានសហជីពចំនួន ១ គឺសហជីពកម្មករនិយោជិតសិប្បកម្មអង្គរនៃក្រុមហ៊ុនសិប្បករចំរុះអង្គរដែលបានបង្កើតឡើងនា ឆ្នាំ២០០៧ ។ ភាគីសហជីពបានបញ្ជាក់នៅក្នុងសវនាការថា សហជីពមានសមាជិកចំនួនប្រមាណ ៥៤១ នាក់ និងប្រមូលប្រាក់ភាគទានសហជីព ដោយសហជីពខ្លួនឯង ប៉ុន្តែសហជីពនេះមិនទាន់ទទួលបានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតនៅឡើយទេ ។

**ចំណុចវិវាទទី ១ : ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលចំនួន ៦ សេន ក្នុងម៉ោងផលិត លើប្រាក់ម៉ោងផលិត ដែលមានស្រាប់**

- ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលចំនួន ៦ សេន សម្រាប់កម្មករនិយោជិត ដែលធ្វើការតាមបរិមាណផលិតផល ហើយដែលជាសមាជិកសហជីពចំនួន ៤៩៩ នាក់ នៅក្នុង ៥ ផ្នែក រួមមានផ្នែកតម្បាញ ផ្នែកសូត្រ ផ្នែកចំលាក់ឈើ ផ្នែកចំលាក់ថ្ម ផ្នែកផ្នែកលាបពណ៌ និង ផ្នែកចំលាក់ស្ពាន់ ។
- ភាគីក្រុមហ៊ុនមិនឯកភាពតាមការទាមទារនេះទេ ព្រោះក្រុមហ៊ុនមានលទ្ធភាពតម្លើងជូនកម្មករនិយោជិត បានតែ ៣ សេនប៉ុណ្ណោះ លើការទាមទារតម្លើង ៦ សេន ។
- ភាគីកម្មករនិយោជិតទទួលស្គាល់ថា ក្រុមហ៊ុនបានតម្លើងចំនួន ៣ សេនរួចហើយ ប៉ុន្តែ ក្នុងករណីនេះ កម្មករនិយោជិតធ្វើការទាមទារតម្លើង ៣ សេន ទៀត ដើម្បីឱ្យគ្រប់ ៦ សេន ដោយសារក្រុមហ៊ុន មានការរីកចំរើន ព្រោះលក់ផលិតផល ដែលកម្មករនិយោជិតផលិតបានដាច់ច្រើន ដោយធ្វើការ ប្រមូលយកទៅលក់មុនការកំណត់ មានរើសកម្មករនិយោជិតថ្មីច្រើន និងបានជូនកម្មករនិយោជិតដើរ កំសាន្តរយៈពេល ៣ ថ្ងៃទៀតផង ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ក្រុមហ៊ុនបានតម្លើងប្រាក់ឈ្នួលនេះ ជាហូរហែរចាប់តាំងពី ឆ្នាំ ២០០៧ មក លើកលែងតែឆ្នាំ២០០៩ទេ ដែលនិយោជកមិនបានតម្លើងប្រាក់ឈ្នួល ដោយសារ ស្ថានភាពសេដ្ឋកិច្ចមិនល្អ ។ ជាក់ស្តែងដូចជា:
    - ឆ្នាំ២០០៧ និយោជិកបានតម្លើងប្រាក់ឈ្នួលចំនួន ៦ សេន រហូតដល់ ៨ សេន អាស្រ័យលើ ភាពប៉ិនប្រសប់របស់កម្មករនិយោជិតម្នាក់ៗ ។
    - ឆ្នាំ២០០៨ និយោជកបានតម្លើង ៥ សេន ស្មើៗគ្នា ដល់កម្មករនិយោជិត ។
    - ឆ្នាំ២០១០ និយោជកបានតម្លើងប្រាក់ឈ្នួលចំនួន ៤ សេន និង
    - ឆ្នាំ២០១១ នេះ និយោជកបានតម្លើងចំនួន ៣ សេន តែកម្មករនិយោជិតទាមទារឱ្យតម្លើង ៣ សេន បន្ថែមទៀត ដោយសារស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមហ៊ុនមានការរីកចំរើន ។

THE ARBITRATION COUNCIL

- ទាក់ទងនឹងការគិតប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលធ្វើការតាមបរិមាណផលិតផល ភាគីកម្មករនិយោជិតបានលើកឧទាហរណ៍ថា ចំពោះការធ្វើការងារលើចំលាក់ឈើ ដែលមានរាងជាអប្សរាផ្កាដូង។ ក្នុងមួយអប្សរាផ្កាដូង ក្រុមហ៊ុនគិតប្រាក់ឈ្នួលឱ្យចំនួន ៥០ ម៉ោង ហើយក្នុងមួយម៉ោងទទួលបានប្រាក់ឈ្នួលចំនួន ០.៣៩ ដុល្លារអាមេរិក។ ដូចនេះ ប្រសិនបើកម្មកររូបណាផលិតបានអប្សរាផ្កាដូងបានចំនួន ១០ អប្សរាក្នុងមួយខែនោះ ប្រាក់ឈ្នួលរបស់ពួកគេនឹងទទួលបាន ៥០ ម៉ោង (ដែលជាម៉ោងផលិតក្នុងអប្សរាផ្កាដូងមួយ) គុណនឹង ១០ អប្សរាផ្កាដូង ដែលផលិតបាន រួចគុណនឹងចំនួនតំលៃនៅក្នុងមួយម៉ោងផលិតចំនួន ០.៣៩ ដុល្លារអាមេរិក។ ជាលទ្ធផល កម្មកររូបនោះ ទទួលបានប្រាក់ឈ្នួលសរុបចំនួន ១៩៥ ដុល្លារអាមេរិកក្នុងមួយខែ។ ភាគីនិយោជកមិនជំទាស់នឹងរបៀបនៃការគណនាប្រាក់ឈ្នួលនេះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ជាមធ្យមកម្មករនិយោជិតធ្វើការតាមបរិមាណផលិតផល ទទួលបានប្រាក់ឈ្នួលជាមធ្យមចំនួនពី ៧០ ទៅ ១៥០ ដុល្លារអាមេរិកក្នុងមួយខែ ហើយជាទូទៅ ម៉ោងផលិត ដែលកំណត់ដោយនិយោជកមិនមានបញ្ហា នោះទេ គឺកម្មករនិយោជិតភាគច្រើនផលិតបាន។
- ភាគីនិយោជកលើកឡើងថា កម្មករនិយោជិតនៅក្នុងក្រុមហ៊ុន សិប្បករអង្គរ បែងចែកជាពីរផ្នែកគឺកម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផល និងកម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួលថេរប្រចាំខែ ដែលរួមមានបុគ្គលិករដ្ឋបាល ពាណិជ្ជកម្ម និងសិប្បករផ្នែកផ្សេងទៀតជាដើម។ ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីនិយោជកបានលើកឡើងនៅក្នុងសារណាសង្ខេបចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ថា សិប្បករម្នាក់ៗធ្វើការងារប្រមាណ ១៩២ ម៉ោងក្នុង១ខែ ដោយមិនរាប់បញ្ចូលនូវម៉ោងធ្វើការបន្ថែមទេ ហើយជាមធ្យម សិប្បករម្នាក់ៗ ទទួលបានម៉ោងស្តង់ដារ (ម៉ោងផលិត) ប្រមាណ ៣៤២ ម៉ោងក្នុង ១ ខែ។ ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីនិយោជកបានបញ្ជាក់នៅក្នុងសារណាដដែលនេះថា កាំប្រាក់ក្នុង ១ ម៉ោង ជាមធ្យមសម្រាប់គ្រប់ផ្នែកមានចំនួន ៣៧ សេន ក្នុង១ម៉ោង លើម៉ោងផលិត។ ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីនិយោជកបានបញ្ជាក់ផងដែរថា និយោជកបានតម្លើងប្រាក់ឈ្នួលចំនួន ៣ សេនក្នុង ១ ម៉ោងផលិតសម្រាប់ឆ្នាំ២០១១ ដោយអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ នេះ សម្រាប់សិប្បករដែលទទួលបានប្រាក់ឈ្នួលតាមបរិមាណផលិតផលទាំងអស់។ ការតម្លើងនេះធ្វើឱ្យប្រាក់ឈ្នួលរបស់សិប្បករសម្រាប់ខែមករា ឆ្នាំ២០១១ ចំនួន ៥០៣ នាក់ ទទួលបានជាមធ្យមពី ១២៧ ទៅ

១៤២ ដុល្លារអាមេរិក ដោយប្រើប្រាស់ម៉ោងផលិតជាមធ្យមសម្រាប់សិប្បករម្នាក់ៗចំនួន ៣៥៦ ម៉ោង ។

- ភាគីនិយោជកបញ្ជាក់នៅក្នុងសវនាការថា ការកំណត់តំលៃលើម៉ោងផលិតជាទូទៅ ក្រុមហ៊ុនពិនិត្យមើលទៅលើទីផ្សារ ការបញ្ជាទិញរបស់អតិថិជន និងស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហើយរៀងរាល់ឆ្នាំមានការពិភាក្សាលើតំលៃនេះជាមួយកម្មករនិយោជិត ដែលជាសិប្បករ ។
- ភាគីនិយោជកបានបញ្ជាក់គោលជំហរថា និយោជកអាចធ្វើការតម្លើងប្រាក់ឈ្នួលបានចំនួនតែ ៣ សេនប៉ុណ្ណោះទៅក្នុងមួយម៉ោងផលិតជូនកម្មករនិយោជិត ដោយសារវត្ថុធាតុដើមឡើងថ្លៃ និង តំលៃផលិតកាន់តែឡើងថ្លៃ ហើយការតម្លើងប្រាក់ឈ្នួលចំនួន ៣ សេន ដល់កម្មករនិយោជិតនៅខែមករានេះ បានធ្វើឱ្យនិយោជកសម្រេចតម្លើងតំលៃសូត្រសម្រាប់លក់ចេញចំនួន ១៥ ភាគរយ ។ ជាក់ស្តែងនៅក្នុងខែកុម្ភៈ ឆ្នាំ២០១១ នេះ ជាលទ្ធផលបង្ហាញថា ចំនួនសូត្រដែលលក់បាន មានការធ្លាក់ចុះព្រោះមានតម្លៃថ្លៃជាងមុន។ បន្ថែមពីនេះទៀត ចំលាក់ថ្ម និងប៉ូលីក្រូមី (ផ្ទៃកលាបពណ៌) ក៏នៅសល់ច្រើន លក់មិនទាន់អស់ទៀត ហើយក្រុមហ៊ុនក៏អាចមានគំរោងនឹងរុះរើទីតាំងរបស់ក្រុមហ៊ុនផងដែរ។ ហេតុដូច្នេះហើយ ក្រុមហ៊ុនត្រូវត្រៀមថវិកាមួយចំនួនសម្រាប់ការផ្លាស់ប្តូរនេះ។ ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការលើកឡើងនេះទេ។
- ភាគីនិយោជកក៏បានលើកឡើងដែរថា វិវាទនេះជាវិវាទអំពីប្រយោជន៍ មិនមែនជាវិវាទ ដែលច្បាប់តំរូវ ឬមានចែងនៅក្នុងអនុសញ្ញារួមនោះទេ។
- ភាគីទាំងពីរបញ្ជាក់ថា កន្លងមកមិនមានកិច្ចព្រមព្រៀង រឺ អនុសញ្ញារួមណាមួយ ដែលភាគីទាំងពីរបានព្រមព្រៀងលើបញ្ហាតម្លើងប្រាក់ឈ្នួលនេះទេ។

## ហេតុផលនៃសេចក្តីសម្រេចៈ

### ចំណុចវិវាទទី ១ : ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលចំនួន ៦ សេន ក្នុងម៉ោងផលិត លើប្រាក់ម៉ោងផលិតដែលមានស្រាប់

ក្នុងករណីនេះ ភាគីក្រុមហ៊ុនបានតម្លើងប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន ៣ សេន ក្នុងមួយម៉ោងផលិត។ ប៉ុន្តែ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលចំនួន ៣ សេនទៀត ដើម្បីឱ្យគ្រប់ ៦ សេន។ ភាគីនិយោជកមិនឯកភាពផ្តល់ជូនតាមការទាមទារនេះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចត្រូវតម្លើងប្រាក់ឈ្នួលចំនួន ៣ សេន បន្ថែមទៀត ដល់កម្មករនិយោជិតដែរ ឬទេ?

ទាក់ទងនឹងការទាមទារតម្លើងប្រាក់ឈ្នួលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិទាក់ទងនឹងច្បាប់ស្តីពីការងារផ្សេងទៀត ចែងអំពីបញ្ហានេះទេ។

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចំរុះសិប្បករអង្គរ ធ្វើនៅខែមីនា ឆ្នាំ២០០៨ ត្រង់ប្រការ ២៤ ចែងថា :

*" ប្រការ ២៤ : ការតំឡើងប្រាក់កំរៃ និង ប្រាក់បៀវត្សរ៍: ក្រុមហ៊ុនសិក្សាជាមួយថ្នាក់គ្រប់គ្រង ដើម្បីតំឡើងប្រាក់កំរៃ ឬប្រាក់បៀបវត្សរ៍ទៅតាមមុខនាទីរបស់សិប្បករនិយោជិតម្នាក់ៗ។ ការតំឡើងប្រាក់កំរៃ ឬបៀវត្សរ៍ ត្រូវបានផ្សារភ្ជាប់ទៅនឹងស្ថានភាពល្អរបស់ក្រុមហ៊ុនផងដែរ និងលទ្ធផលការងាររបស់សិប្បករនិយោជិត។ ការតំឡើងប្រាក់បៀវត្សរ៍ចែកចេញជា២ប្រភេទផ្សេងគ្នា គឺជាលក្ខណៈបុគ្គល និងជាលក្ខណៈទូទៅ។ ការតំឡើងប្រាក់កំរៃ ឬបៀវត្សរ៍ជាលក្ខណៈបុគ្គល : ការតំឡើងប្រាក់បៀវត្សរ៍ជាលក្ខណៈបុគ្គល សម្រេចធ្វើឡើងដោយថ្នាក់ដឹកនាំក្រុមហ៊ុន យោងតាមការលូតលាស់ និងសមត្ថភាពរបស់សិប្បករនិយោជិតម្នាក់ៗ។ ការតំឡើងប្រាក់បៀវត្សរ៍ ជាលក្ខណៈទូទៅៈយោងទៅលើស្ថានភាពសេដ្ឋកិច្ចទីផ្សារ និងស្ថានភាពក្រុមហ៊ុន ថ្នាក់ដឹកនាំអាចសម្រេចដំឡើងប្រាក់បៀវត្សរ៍ ឬ កាំប្រាក់ "* ។

យោងតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការតំឡើងប្រាក់កំរៃ ឬបៀវត្សរ៍ត្រូវបានផ្សារភ្ជាប់ទៅនឹងស្ថានភាពល្អរបស់ក្រុមហ៊ុន និងលទ្ធផលការងាររបស់សិប្បករនិយោជិត តាមរយៈការសិក្សាជាមួយថ្នាក់គ្រប់គ្រង ដោយយោងផងដែរលើស្ថានភាពសេដ្ឋកិច្ចទីផ្សារ និងស្ថានភាពក្រុមហ៊ុន សម្រាប់ការតំឡើងប្រាក់បៀវត្សរ៍ជាលក្ខណៈជាទូទៅ។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់ឈ្នួលចំនួន ៦ សេន ទៀត។ ចំណែកឯភាគីនិយោជកមិនអាចតម្លើងជូន៦សេនបានទេ គឺអាចតម្លើងជូនបានតែចំនួន ៣ សេន ប៉ុណ្ណោះ ព្រោះវត្ថុធាតុដើមឡើងថ្លៃ ហើយចំណែកការលក់មានការធ្លាក់ចុះ ព្រោះត្រូវលក់ក្នុងតម្លៃថ្លៃជាងមុន។ បន្ថែមពីនេះទៀតចំលាក់ថ្ម និងប៉ូលីគ្រូមី (ផ្ទៃកលាបពណ៌) ក៏នៅសល់ច្រើន លក់មិនទាន់អស់ទៀត ហើយក្រុមហ៊ុនក៏ត្រូវត្រៀមថវិកាមួយចំនួនសម្រាប់ការផ្លាស់ប្តូរទីតាំងដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុនបានបំពេញកាតព្វកិច្ចតាមបទបញ្ជាផ្ទៃក្នុង ដោយពិចារណាទៅលើស្ថានភាពរបស់ក្រុមហ៊ុន ស្ថានភាពទីផ្សារ មុននឹងធ្វើការសម្រេចចិត្តតម្លើងប្រាក់ឈ្នួល ឬតម្លើងកាំប្រាក់ដល់កម្មករនិយោជិត។ លើសពីនេះ បទបញ្ជាផ្ទៃក្នុងខាងលើ គ្មានការចែងអំពីការតម្លើងប្រាក់ឈ្នួល ៦ សេននេះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនមានមូលដ្ឋានច្បាប់ ឬកិច្ចព្រមព្រៀងណាមួយ ដើម្បីគាំទ្រការទាមទាររបស់ខ្លួននោះទេ។ ដូច្នេះ ការទាមទារនេះជាវិវាទអំពីផលប្រយោជន៍។

ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ។ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធ

ពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះមក ជាសហជីពដែលមិនមានភាពជាតំណាងបំផុតនៅក្នុងរោងចក្រ។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល *លេខ ៨១/០៤-អេវើគ្រីន ហេតុផលចំណុចវិវាទទី៤, លេខ ០៩/០៥-គីន តាយ ហេតុផលចំណុចវិវាទទី២, លេខ ៨៤/០៧-យ៉ុង វ៉ា ២ ហេតុផលចំណុចវិវាទទី១, លេខ ១០៨/០៧-៨ ស្ដារ ស្ពតវែរ ហេតុផលចំណុចវិវាទទី៣, លេខ ១៣៥/០៧-វិល សិន ហេតុផលចំណុចវិវាទទី១, លេខ ១៤/០៨-ឃ្វីក ស៊ូ ហេតុផលចំណុចវិវាទទី៣, លេខ ១០១/០៨-ជី ឌី អឹម ហេតុផលចំណុចវិវាទទី៣ និងលេខ ៤២/០៩ ហេតុផល ចំណុចវិវាទទី២)*។

នៅក្នុងសំណុំរឿងមុនៗក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្ដល់គុណវុឌ្ឍិផ្នែកផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងវិវាទអំពីប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការដោះស្រាយ។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ *៥៧/០៤-អេវើហ្គ្រីន ៦០/០៤-យូណាយ ធិតអាត ហេតុផលនៃសេចក្ដីសំរេច ចំណុចវិវាទទី៣ ០៨/០៧-ស៊ាវ តិញ ហេតុផលនៃសេចក្ដីសំរេច ចំណុចវិវាទទី៣)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា សហជីពកម្មករនិយោជិតសិប្បកម្មអង្គរនៃក្រុមហ៊ុន សិប្បករចំរុះអង្គរ មិនទាន់មានភាពជាតំណាងបំផុតនៅឡើយទេ។ ហេតុដូច្នេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សហជីពកម្មករនិយោជិតសិប្បកម្មអង្គរនៃក្រុមហ៊ុន សិប្បករចំរុះអង្គរ មិនទាន់មានសិទ្ធិស្របតាមផ្លូវច្បាប់ក្នុងការនាំវិវាទពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការដោះស្រាយទេ ហើយនិយោជកក៏មិនមានកាតព្វកិច្ចត្រូវតម្លើងប្រាក់ឈ្នួលចំនួន ៣ សេន បន្ថែមទៀតដល់កម្មករនិយោជិតដែរ។

សរុបសេចក្ដីមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបដិសេធពិចារណា លើការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ៣ សេន ទៀត ដើម្បីឱ្យគ្រប់ ៦ សេន ក្នុងមួយម៉ោងផលិត។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ :** បដិសេធពិចារណាលើការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួល ៣ សេន ទៀត ដើម្បីឱ្យគ្រប់ ៦ សេន ក្នុងមួយម៉ោងផលិត។៤

THE ARBITRATION COUNCIL

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ុក រី**

ហត្ថលេខា: -------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណាន**

ហត្ថលេខា: -------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: -------------------------------